## សាលារៀនផ្តើមបើកនៅថ្ងៃទី31 ខែសីហា

សាលារៀននឹងផ្តើមបើកនៅថ្ងៃអង្គារ ទី31 ខែសីហា សម្រាប់សិស្សភាគច្រើននៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ ឡុងប៊ីច ។ ក្រសួងអប់រំ ឱស្រ្ទីគ រៀបគម្រោងទទួលសិស្សចូលរៀនក្នុងថ្នាក់ផ្ទាល់ យ៉ាងពេញកម្រិតម៉ោង ។ ទម្រង់ការផ្នែកសុខភាព និង សុវត្ថិភាពនឹងប្រើតាមជាបន្ត ដើម្បីការពារភាពរាលដាលនៃជម្ងឺ កូវីដ ។ ទម្រង់ការទាំងអស់នឹងមានលើកបង្ហាញជាសេចក្តីសង្ខេបនៅក្នុង **គោលការណ៍ណែនាំសម្រាប់ក្រុមគ្រួសារនៅពេលបើកសាលារៀន** ។

សាលារៀនភាគច្រើននឹងបើកទ្វារធ្វើការឡើងវិញនៅថ្ងៃសុក្រ ទី20 ខែសីហា ។ សូមបើកមើល គេហទំព័រ នៅតាមសាលារៀននិមួយៗ សម្រាប់ដំណឹងអំពីការត្រឡប់ចូលរៀនវិញ ។ ការបើកមើល គេហទំព័រ នៅតាមសាលារៀននិមួយៗ គឺអាចធ្វើបាន ដោយបើកចូលទៅកាន់ lbschools.net និង ចុចយក A-Z Index ។ សាលារៀន Sato Academy of Mathematics and Science និង សាលារៀន California Academy of Mathematics and Science នឹងមិនប្រើថ្ងៃទី31 ខែសីហា នោះទេសម្រាប់ផ្តើមឆ្នាំសិក្សាថ្មី ។ សាលារៀនទាំង ពីរ កន្លែង គឺ Sato និង CAMS នឹងបើកឆ្នាំសិក្សាទទួលសិស្សចូលរៀននៅ ថ្ងៃពុធ ទី18 ខែសីហា ។

ចំពោះក្រុមគ្រួសារ ដែលប្រាថ្នាចង់បានកម្មវិធីបង្ហាត់មេរៀនផ្សេង ក្រៅពីការចូលរៀនក្នុងថ្នាក់ផ្ទាល់ពេញម៉ោង គឺក្រសួងអប់រំ ឱស្រ្ទីគ កំពុងផ្តល់ការជ្រើសរើសយកកម្មវិធីរៀនជាឯករាជ្យភាពបានសម្រាប់សិស្សថ្នាក់ ធី-ឃេ ទៅ ថ្នាក់ទី ដប់ពីរ ។ ដំណឹងបន្ថែមនឹងមានផ្តល់ជូនជាបន្តនៅក្នុងសប្តាហ៍ខាងមុខ ។

**ការចុះឈ្មោះចូលរៀន និង ការចាក់ថ្នាំបង្ការរោគ**
ការចុះឈ្មោះចូលរៀនទុកជាមុនសម្រាប់សិស្សថ្មីមកកាន់ក្រសួងអប់រំ ឱស្រ្ទីគ គឺធ្វើតាមរយៈទៅដល់មុន ទទួលការចុះឈ្មោះមុន នៅតាមសាលារៀននិមួយៗ ។ ការសុំរៀននៅតាមសាលាប្រចាំតំបន់ ឬ នៅក្បែរផ្ទះ គឺគ្មានធានាទេ ដោយសំអាងលើកន្លែងមាន ឬ មិនមាន ។ បើសិនជាកន្លែងនៅតាមសាលាប្រចាំតំបន់ ឬ នៅក្បែរផ្ទះពេញអស់ទៅ គឺមាតាបិតានឹងទទួលដំណឹងប្រាប់អំពីកន្លែងនៅតាមសាលាផ្សេងនៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ ដែលសិស្សរបស់ពួកគាត់នឹងបញ្ជូនឱ្យទៅរៀនជាមួយ ។ ដើម្បីចុះឈ្មោះចូលរៀនក្នុងថ្នាក់ មត្តេយ្យ បាន គឺសិស្សត្រូវមានអាយុ ប្រាំ ឆ្នាំទាន់ ថ្ងៃទី1 ខែកញ្ញា យោងតាមច្បាប់របស់រដ្ឋ ។ សូមឆែកមើលនៅតាមសាលារៀននិមួយៗអំពីពេលវេលាដែលគេបើកទទួលការចុះឈ្មោះទុកជាមុនសម្រាប់សិស្សថ្មី ដែលនឹងចូលរៀននៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ ។

ចំពោះសិស្សមាន មេឌីខែល ឬ ការរ៉ាប់រងផ្នែកសុខភាព គឺគួរជួបវេជ្ជបណ្ឌិតរបស់គេសម្រាប់ទទួលការចាក់ថ្នាំបង្ការរោគចាំបាច់ មុននឹងដល់ពេលចូលរៀន ។ ចំពោះសិស្សគ្មានការរ៉ាប់រងផ្នែកសុខភាពវិញ គឺគេអាចទទួលការចាក់ថ្នាំបង្ការរោគបានតាមរយៈពេលណាត់ជួបតែប៉ុណ្ណោះជាមួយក្រសួងសុខាភិបាលប្រចាំក្រុង ឡុងប៊ីច ស្ថិតនៅ ... 2525 Grand Ave., Long Beach, CA 90815 ។ ពេលណាត់ជួបគឺអាចធ្វើបាន ដោយទាក់ទងតាមទូរស័ព្ទលេខ (562) 570-4315 ។ ដើម្បីឆែកមើលច្បាប់តម្រូវអំពីការចាក់ថ្នាំបង្ការរោគ គឺសូមបើកចូលទៅកាន់ lbschools.net ក្រោមពាក្យ Immunizations នៅតាម A-Z Index ។

**ថ្នាក់រៀន មុនពេលចូលថ្នាក់មេត្តេយ្យ** (ធី-ឃេ) គឺកំពុងតែបើកទទួល ក្នុងការឆ្លើយតបទៅកាន់ច្បាប់កាលពីឆ្នាំ2010 ដែលបានធ្វើការកែប្រែមកលើថ្ងៃ ខែចូលរៀនសម្រាប់ថ្នាក់មត្តេយ្យ ពីថ្ងៃទី2 ខែធ្នូ ទៅកាន់ ថ្ងៃទី1 ខែកញ្ញា វិញ ។ ថ្នាក់ ធី-ឃេ ដែលផ្តល់ឱកាសរៀនទៅកាន់ក្មេងមានកំណើតក្នុងរដូវស្លឹកឈើធ្លាក់ គឺជាកម្មវិធីឆ្នាំទីមួយក្នុងចំនួន ពីរ ឆ្នាំ សម្រាប់ទទួលពួកគេរៀន បើសិនជាមានកំណើតនៅក្នុងចន្លោះថ្ងៃទី2 ខែកញ្ញា និង ថ្ងៃទី2 ខែធ្នូ ។ ថ្នាក់នេះរៀបចំឡើងស្របអាយុរបស់សិស្ស ដែលមានគ្រូបង្រៀនពេញច្បាប់ធ្វើការមើលខុសត្រូវ ។ មាតាបិតាមានសិទ្ធិចុះឈ្មោះឱ្យសិស្សចូលរៀនក្នុងថ្នាក់ ធី-ឃេ បាន ឬ រង់ចាំមួយឆ្នាំបន្ថែម ទំរាំតែដល់ពេលសិស្សគ្រប់អាយុចូលរៀនថ្នាក់មត្តេយ្យ ។ ការចុះឈ្មោះចូលរៀននឹងធ្វើនៅតាមសាលារៀន ។

ដើម្បីយល់ដឹងបន្ថែមអំពីថ្នាក់ ធី-ឃេ គឺសូមបើកចូលទៅកាន់ lbschools.net ក្រោមពាក្យ Transitional Kindergarten នៅតាម A-Z Index ។

ការចុះឈ្មោះចូលរៀននឹងធ្វើនៅតាមសាលាប្រចាំតំបន់ ឬ នៅក្បែរផ្ទះ មិនមែននៅតាមការិយាល័យនៃក្រសួងអប់រំ ឌីស្ទ្រីគ នោះទេ ។ ដើម្បីយល់ដឹងបន្ថែមអំពីរបៀបចុះឈ្មោះចូលរៀន រួមទាំងក្រដាសស្នាមចាំបាច់ផ្សេងៗទៀតផង គឺសូមបើកចូលទៅកាន់ lbschools.net ក្រោមពាក្យ Enrollment នៅតាម A-Z Index ។

**អាហារនៅតាមសាលារៀន**

ក្នុងឆ្នាំសិក្សា 2021-22 គឺអាហារសម្រាប់សិស្សទាំងអស់នឹងគ្មានទាមទារការបង់លុយទេ ។ យ៉ាងណាក៏ដោយ យើងសូមជម្រុញដល់ក្រុមគ្រួសារឱ្យធ្វើការឆ្លើយបំពេញក្រដាសដាក់ពាក្យទទួលអាហារ ដើម្បីឱ្យក្រសួងអប់រំ ឌីស្ទ្រីគ អាចនៅតែបន្តទទួលជាថវិកាទ្រទ្រង់បាន ។ ដើម្បីយល់ដឹងបន្ថែមអំពីក្រសួងចែកផ្តល់អាហារ គឺសូមបើកមើលនៅតាម គេហទំព័រ Meal Application page ។

**កន្លែងជួប ឡានបឹស និង ផ្លូវដឹកជញ្ជូន**

សម្រាប់ការយល់ដឹងអំពីសិស្ស ដែលមានសិទ្ធិទទួលការដឹកជញ្ជូនតាមឡាន បឹស គឺសូមឆែកមើលនៅក្នុង ParentVue ចំនួនមួយសប្តាហ៍មុននឹងសាលារៀនចាប់ផ្តើម ។ សម្រាប់សំនួរផ្សេងៗអំពីកន្លែងរៀន ឬ ប្រភេទនៃជំនួយ គឺគួរធ្វើការទាក់ទងផ្ទាល់ទៅកាន់អ្នកគ្រប់គ្រងសំណុំរឿងនៃសិស្សនៅតាមសាលា ដែលគេនឹងចូលរៀនជាមួយ ។ សម្រាប់សំនួរផ្សេងៗអំពីឡាន បឹស គឺអាចធ្វើការទាក់ទងទៅកាន់ការិយាល័យដឹកជញ្ជូនតាមទូរស័ព្ទលេខ (562) 424-5195 ។

ក្រសួងដឹកជញ្ជូនសាធារណៈ ហៅ Long Beach Transit ទទួលស្គាល់ការប្រើ TAP ដែលជា កាដ ប្លាស្ទិក មាន smart chip នៅខាងក្នុង ។ Long Beach Transit បើកផ្តល់ជាក្រដាសដាក់ពាក្យសម្រាប់ការបញ្ចុះតម្លៃទៅកាន់សិស្ស និង សិស្សមានភាពពិការ បើសិនជាគេទិញ កាដ TAP សម្រាប់ប្រើក្នុងរយៈពេល 30 ថ្ងៃ ។ មាតាបិតាត្រូវរំលឹកប្រាប់សិស្សថា ពួកគេនឹងគោរពតាមច្បាប់សាលារៀន នៅពេលជិះឡាន បឹស សាធារណៈទៅមកពីសាលារៀន ។

សម្រាប់សំនួរបន្ថែមអំពីការត្រឡប់ចូលសាលារៀនវិញ គឺសូមធ្វើការទាក់ទងសាលារៀនរៀងៗខ្លួន ឬ ទៅកាន់ការិយាល័យដូចតទៅ ...

- ផ្នែកបឋមសិក្សា - (562) 997-8247
- ផ្នែកមធ្យមសិក្សា/K-8 - (562) 997-8100
- ផ្នែកវិទ្យាល័យ - (562) 997-8115